ប្រវត្តិវិទ្យា

១២



ជំពូកទី ២ មេរៀនទី៥

សាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា (១៩៧៩-១៩៩៣)

បង្រៀនដោយ៖ លោកគ្រូ **មាស ភិរុណ**


វិទ្យាល័យ ព្រះស៊ីសុវត្ថិ

MEAS PHYRUN

កំណែកិច្ចការផ្ទះ

តើប្អូនចង់បានការដឹកនាំប្រទេសតាមបែប
របបកម្ពុជាប្រជាធិបតេយ្យដែរ ឬទេ ?
ព្រោះអ្វី ?





ទប់ស្កាត់របបប្រល័យពូជសាសន៍មិនឱ្យកើតសារជាថ្មី

ឆ្លើយតបនឹងរបបប្រល័យពូជសាសន៍


ផ្សះផ្សារបួសផ្លូវចិត្ត

ស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ

រំឭកមេរៀន

តើសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមបង្កើតឡើងក្នុងបំណងអ្វី?





សាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩)





សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

រដ្ឋកម្ពុជា (១៩៨៩-១៩៩១)





អ៊ុនតាក់(១៩៩១-១៩៩៣)



១. ការរំដោះប្រទេសពីរបបកម្ពុជាប្រជាធិបតេយ្យ

១.១. កំណើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា



- ការបះបោរប្រឆាំងប៉ុល ពត
  - ខែមករា ឆ្នាំ១៩៧៦ លោក ហ៊ូ នឹម ចេញមុខប្រឆាំងនឹងប៉ុល ពត
  - ខែមីនា ឆ្នាំ១៩៧៦ ប្រជាជននៅចម្ការហ្លួង និងនៅខេត្តសៀមរាប ទាមទារឱ្យតម្លើងកម្រិតជីវភាព និងឱ្យគ្រួសាររស់នៅជួបជុំគ្នា
  - ឆ្នាំ១៩៧៧ ប្រជាជននៅសៀមរាប បាត់ដំបង កំពង់ធំ កំពង់ឆ្នាំង មណ្ឌលគីរី ចម្ការហ្លួង បះបោរប្រឆាំងប៉ុល ពត

សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

❖ ការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា


- នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានបង្កើតឡើងក្នុងមូលដ្ឋានស្រុកស្នួល ដែលមានសមមិត្ត ហេង សំរិន ជាប្រធាន។








សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)



សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

- **កម្មវិធីនយោបាយ:**
  - គោរពឆន្ទៈ និងគោលបំណងរបស់ប្រជាពលរដ្ឋ
  - ផ្តួលរំលំពួកប្រតិកិរិយាប៉ុល ពត ដែលជាពួកឃាតក
  - កសាងប្រទេសកម្ពុជា ប្រកបដោយ ឯករាជ្យ សន្តិភាព សេរីភាព និងសុភមង្គល





១.២. ជ័យជម្នះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩:

ដោយមានការគាំទ្រពីកងទ័ពវៀតណាម រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានបើកការ វាយប្រហារលើកងទ័ពខ្មែរក្រហមនាថ្ងៃទី**២៥ ខែធ្នូ ឆ្នាំ១៩៧៨** និងទទួលបានជ័យជម្នះនៅថ្ងៃទី **៧ ខែមករា ឆ្នាំ១៩៧៩** ។








សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

- អត្ថន័យថ្ងៃ៧ មករា


២. សាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩)

ក្រោយពីជោគជ័យលើរបបកម្ពុជាប្រជាធិបតេយ្យ នាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបថ្មីមួយបានចាប់បដិសន្ធិឡើងក្រោមជំនួយឧបត្ថម្ភពីកម្លាំងកងទ័ពវៀតណាម គឺ **របបសាធារណរដ្ឋប្រជាមានិតកម្ពុជា**។ កិច្ចការចាំបាច់គឺ **ការកសាងសន្តិភាព** និង **ការស្ថាបនាជាតិ** ឡើងវិញ។





២.១. អង្គការគ្រប់គ្រងសំខាន់ៗនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា



សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

❖ គណបក្សប្រជាជនបដិវត្តន៍កម្ពុជា







លោក ប៉ែន សុវណ្ណ → អគ្គលេខាបក្ស(១៩៨១) → លោក ហេង សំរិន

❖ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា(ក្រុមប្រឹក្សារដ្ឋមន្ត្រី)

ជាអ្នកសម្រេចទិសដៅសំខាន់ៗរបស់បក្ស ដោយចាត់វិធាការរដ្ឋបាលយ៉ាងច្បាស់លាស់សម្រាប់រដ្ឋមន្ត្រីយកទៅផ្សព្វផ្សាយតាមក្រសួង និងឱ្យក្រសួងរាយការណ៍ពីសមិទ្ធផល និងបញ្ហាប្រឈមផ្សេងៗ...



លោក ប៉ែន សុវណ្ណ



លោកចាន់ ស៊ី(១៩៨១-១៩៨៤)



លោក ហ៊ុន សែន

សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

❖ **ក្រុមប្រឹក្សារដ្ឋ** : មានតួនាទីធ្វើការវិនិច្ឆ័យ លើបញ្ហាច្បាប់ ដូចជារៀបចំច្បាប់ ក្រមព្រហ្មទណ្ឌ និងកែប្រែទោសប្រហារជីវិតជាដើម..








លោក ហេង សំរិន ជាប្រធានក្រុមប្រឹក្សារដ្ឋ (ប្រមុខរដ្ឋ)

សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

❖ **រដ្ឋសភាជាតិ : ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ សភាបានអនុម័តរដ្ឋធម្មនុញ្ញ។**

សភាមាន១១៧អាសនៈ។








លោក ជា ស៊ីម ជាប្រធានរដ្ឋសភា

២.២. សមាសភាពគ្រប់គ្រងនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា




៣. ការកសាងសន្តិភាព និងការកសាងជាតិឡើងវិញ

៣.១.ខ្មែរទាំង៤ភាគី


- ១.សាធារណរដ្ឋប្រជាមានិតកម្ពុជា
- ២.កម្ពុជាប្រជាធិបតេយ្យ
- ៣. រណសិរ្សបង្រួបបង្រួមជាតិដើម្បីកម្ពុជាឯករាជ្យ អព្យាក្រឹត សន្តិភាព និងសហប្រតិបត្តិការ (FUNCINPEC)
- ៤.រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ

សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

៣.២. សង្គ្រាមក្នុងស្រុក



សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)



៣.៣. ការទប់ស្កាត់ការវិលត្រឡប់របស់ពួកខ្មែរក្រហម :

❖ កិច្ចការពារសន្តិសុខ :


ដើម្បីការពារសន្តិសុខរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបាន៖

- បង្កើតកងសេនាជនភូមិ ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់តាមភូមិ ឃុំ
- បង្កើតក្រុមស្ម័យការពារ ក្រុមយាមកាម ដែលតម្រូវឱ្យសិស្ស និស្សិត មន្ត្រីរដ្ឋ ការចូលរួម និងហ្វឹកហាត់ក្បួនយោធាដល់ សិស្ស និស្សិត
- បង្កើតកាតព្វកិច្ចយោធា(ថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៨៥) ដែលតម្រូវឱ្យយុវជន ចាប់ពីអាយុ១៨ឆ្នាំឡើងទៅចូលបម្រើកងទ័ព

សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

❖ ការរំដោះតាមព្រំដែន :

- រៀងរាល់រដូវប្រាំងចាប់ពីឆ្នាំ១៩៧៩-១៩៨៤ កងទ័ពរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា បានវាយសម្រុកលើខ្មែរក្រហម និងដណ្តើមគ្រប់គ្រងតំបន់មួយចំនួនតាមព្រំដែន តែដកទ័ពនារដូវវស្សា
- ១៩៨៤ កងទ័ពវាយលុកលើខ្មែរក្រហមទាំងរដូវប្រាំង និងរដូវវស្សា



សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

❖ ផែនការ ក៥ :

ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៨៤ ការិយាល័យនយោបាយមជ្ឈឹមបក្សបានចេញសេចក្តីសម្រេចចិត្តមួយស្តីពីការបង្កើនការការពារនៅតាមព្រំដែនកម្ពុជា-ថៃ ដោយឱ្យឈ្មោះថា « ផែនការ ក៥ : កែនកម្លាំងកាប់ឆ្ការព្រៃការពារព្រំដែនកម្ពុជា»៖


- សាងសង់ផ្លូវតាមព្រំដែនកម្ពុជា-ថៃ
- កាប់ឆ្ការព្រៃ
- រៀបចំប្រព័ន្ធការពារតាមបណ្តោយព្រំដែនកម្ពុជា-ថៃ





សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

៣.៤. ការកសាងជាតិឡើងវិញ



សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

❖ ស្ថានភាពសង្គមកម្ពុជាក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ :

- ប្រជាជនកម្ពុជាបានវិលត្រឡប់មកស្រុកកំណើតវិញ ដើម្បីជួបជុំគ្រួសារ ប៉ុន្តែ
  - ពុំមាននរណាម្នាក់ដែលពុំបានបាត់បង់សាច់ញាតិទេ
  - អ្នកខ្លះបានស្លាប់ផុតពូជ
- ប្រជាជនខ្លះទៀតដោយអស់សង្ឃឹមនឹងរស់នៅស្រុកខ្មែរ ក៏បានភៀសខ្លួនទៅរស់នៅក្នុងជំរុំតាមព្រំដែនកម្ពុជា ថៃ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។



ជំរុំខៅអ៊ីដាង

សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

- ប្រជាជនប្រមាណ៨0%គិតតែពីដើរកបងប្អូនសាច់ញាតិ ពុំបានធ្វើស្រែចំការ បង្កបង្កើនផល
- អ្នកនៅរស់ភាគច្រើនជាស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរា ជនបាក់កម្លាំង គ្មានទីពឹងគ្មានឧបករណ៍ធ្វើស្រែចម្ការ
- ប្រជាជនរស់នៅដោយកង្វះសម្លៀកបំពាក់ កង្វះអាហារ រងគ្រោះទន្លឹក្ស ព្រោះមុននឹងចាកចេញខ្មែរក្រហមបានដុតបំផ្លាញស្បៀងអាហារចោលស្ទើរអស់





សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

❖ ការស្ថាបនាសេដ្ឋកិច្ច: បញ្ហាបន្ទាន់គឺ បញ្ហាស្បៀងដូចនេះរដ្ឋាភិបាលបាន៖

- អំពាវនាវសុំជំនួយពីសហគមន៍អន្តរជាតិ ទាំងស្បៀង ពូជនិងសម្ភារប្រើប្រាស់
- បង្កើតក្រុមសាមគ្គីបង្កបង្កើនផលដើម្បីជួយដល់ស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរា
- ឆ្នាំ១៩៨០ បោះពុម្ពក្រដាសប្រាក់ឱ្យចាយវាយទូទាំងប្រទេស
- ឆ្នាំ១៩៨៣-១៩៨៦ ប្តូរពីក្រុមសាមគ្គីបង្កបង្កើនផល ទៅជាម្ចាស់ការទាំងស្រុង ដោយធ្វើការបែងចែកដីធ្លី និងឈានទៅរកកម្មសិទ្ធិឯកជន
- អនុវត្តមុខព្រួញទាំង៤នៃសេដ្ឋកិច្ច

សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

ក្រដាសប្រាក់កម្ពុជា បោះពុម្ពឆ្នាំ១៩៧៩:

















សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

❖ **ការស្ដារនាសង្គម:** កម្ពុជាជួបនូវកង្វះខាតធនធានមនុស្ស កង្វះថវិកា...និងរងនូវគំនាបរបស់ប្រទេសមហាអំណាចសេរី និងប្រទេសជាសម្ព័ន្ធមិត្ត។

- **វិស័យអប់រំ :** ប្រព័ន្ធអប់រំត្រូវបានស្ដារឡើងវិញដោយ ៖
  - បើកទ្វារសាលាគ្រប់ភូមិសិក្សា ដល់ឧត្តមសិក្សាទទួលសិស្សឱ្យចូលរៀនតាំងពីទីក្រុងដល់ជនបទ
  - ធ្វើការជួសជុល និងសាងសង់សាលារៀនបន្ថែម
  - ធ្វើការជ្រើសរើស និងបណ្ដុះបណ្ដាលគ្រូបង្រៀន

សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

- អំពាវនាវឱ្យឪពុក ម្តាយ អាណាព្យាបាលយកកូន ក្មួយ ចៅ ទៅសាលារៀន
- ជំរុញនិងបំផុសចលនាអនក្ខរកម្ម និងបំពេញវិជ្ជា
- អនុវត្តនយោបាយ«អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ»
- បង្កើតអន្តេវាសិកដ្ឋានសម្រាប់សិស្ស និស្សិតស្នាក់នៅរៀនសូត្រ
- បញ្ជូនសិស្ស និស្សិតទៅសិក្សានៅបរទេស និងអញ្ជើញគ្រូបរទេសមកបង្ហាត់បង្រៀនកូនខ្មែរនៅក្នុងប្រទេស

សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

- **វិស័យវប្បធម៌:** បើកសេរីភាពដល់ជំនឿ សាសនា ប្រពៃណីទំនៀម ទម្លាប់ និងបើកទ្វារសាលាវិចិត្រសិល្បៈ ប្រមូលផ្តុំសិល្បករ
- **វិស័យសង្គមកិច្ច :** បង្កើតមជ្ឈមណ្ឌលកុមារកំព្រា បង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ជនពិការ និងស្ត្រីមេម៉ាយ បង្កើតច្បាប់ការពារកម្មសិទ្ធិឯកជន (**១៩៨៧**)
- **វិស័យសុខាភិបាល :** បើកទ្វារមន្ទីរពេទ្យទទួលពិនិត្យនិងព្យាបាលជំងឺ បើកទ្វារសាលាបណ្តុះបណ្តាលពេទ្យ មានមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ

៥. ការចរចារកសន្តិភាព និងការបង្រួបបង្រួមជាតិ



❖ ព្រឹត្តិការណ៍អន្តរជាតិដែលផ្តល់បច្ច័យល្អដល់កម្ពុជា

- កំណែទម្រង់ពេរ៉ែស្តូយកា(១៩៨៥)
- កំណែទម្រង់ដូយមឺយ (១៩៨៦)
- ដំណើរទស្សនកិច្ចរបស់លោកអាលីអាឡាតាស់នៅវៀតណាម(១៩៨៧)
- ជំនួបកំពូលរវាងសហរដ្ឋអាមេរិកនិង សហភាពសូវៀត(១៩៨៧)
- សូវៀតដកទ័ពចេញពីប្រទេសអាហ្វហ្គានីស្ថាននិងដកក្បាលកាំជ្រួចចេញពីតំបន់ស៊ីបេរី(១៩៨៩)

៥. ការចរចារកសន្តិភាព និងការបង្រួបបង្រួមជាតិ

❖ ការដកទ័ពវៀតណាមចេញពីកម្ពុជា

វៀតណាមបានធ្វើកំណែទម្រង់ដូយមុីយ (**១៩៨៦**) ដែលបណ្តាលឱ្យវៀតណាមផ្លាស់ប្តូរ ឥរិយាបថនយោបាយការបរទេស ដូចជាការប្រកាសដកជំនាញការ និងដកកងទ័ពចេញពីកម្ពុជា(**ថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៨៩**) និងដកទ័ពចេញពីកម្ពុជាទាំងស្រុងនាថ្ងៃទី**២១ ខែកញ្ញា ឆ្នាំ១៩៨៩**





សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

❖ វិសោធនកម្មរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា





ថ្ងៃទី២៩-៣០ ខែមេសា ឆ្នាំ១៩៨៩

សភានៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា បានប្រជុំវិសាមញ្ញនិងសម្រេចធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដូចជា៖

- ប្តូរឈ្មោះប្រទេសពីសាធារណរដ្ឋប្រជាមានិតកម្ពុជា ទៅជារដ្ឋកម្ពុជា
- ប្តូរទង់ជាតិ ភ្លេងជាតិ





សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

- លុបចោលនូវទោសប្រហារជីវិត (លុបចោលច្បាប់ប្រហារជីវិត)
- លើកតម្កើងព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ និងលុបចោលនូវការកំហិតអាយុអ្នកសាងផ្នួស
- បង្កើតច្បាប់ការពារកម្មសិទ្ធិឯកជន និងទីផ្សារសេរី
- ផ្តល់សេរីភាពដល់សារព័ត៌មាន និងការបង្កើតអង្គការសង្គមស៊ីវិល
- លុបចោលនូវពាក្យ សង្គមនិយម កុម្មុយនីស្ត ក្នុងអត្ថបទច្បាប់
- រដ្ឋធម្មនុញ្ញបានចែងថា “កម្ពុជាអនុវត្តនយោបាយអព្យាក្រឹតមិនចូលបក្សសម្ព័ន្ធ” នេះជាការបើកផ្លូវឱ្យរដ្ឋាភិបាលធ្វើការចរចាបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា។

៥. ការចរចារកសន្តិភាព និងការបង្រួបបង្រួមជាតិ

❖ ការចរចារកសន្តិភាព

- ព្រឹត្តិការណ៍អន្តរជាតិបានផ្តល់បច្ច័យល្អក្នុងការចរចារកសន្តិភាពនៅកម្ពុជា
- នៅ**ខែវិច្ឆិកា ឆ្នាំ១៩៨៤** គម្រោងជួបចរចានៅបារាំងរវាង តំណាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសម្តេច**នរោត្តម សីហនុ** បរាជ័យដោយសារសាធារណរដ្ឋប្រជាមានិតចិន និងខ្មែរក្រហមដាក់គំនាបលើព្រះអង្គ

សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

- ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧ ជំនួបរវាងសម្តេចនរោត្តម សីហនុ និងលោកហ៊ុន សែន នៅទីក្រុងហ្វៃអង់តាដឺន័រ ដោយបានព្រមព្រៀងគ្នារកដំណោះស្រាយវិបត្តិនៅកម្ពុជា
- ដោយមានអន្តរាគមន៍របស់បរទេសលោក សឺន សាន និងលោក ខៀវ សំផនព្រមចូលតុចរចា





សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

- **ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៨៨** ការចរចាលើកដំបូងរវាងភាគីទាំង៤ និងប្រទេសពាក់ព័ន្ធនៅឥណ្ឌូនេស៊ី ។ ជាលទ្ធផល
  - ការកំណត់ដកកងទ័ពវៀតណាមចេញពីកម្ពុជា
  - ការទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឱ្យត្រឡប់មកវិញ
  - ការបញ្ឈប់ជំនួយបរទេសទៅឱ្យក្រុមប្រឆាំងនឹងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា
  - ការបញ្ឈប់ការជ្រៀកជ្រែកពីខាងក្រៅក្នុងកិច្ចការរបស់កម្ពុជា


សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

- វេទិការបស់សម្តេចនរោត្តម សីហនុ និងឯកឧត្តម ហ៊ុន សែន ដើម្បីស្វែងរកដំណោះស្រាយវិបត្តិនយោបាយនៅកម្ពុជាបានប្រព្រឹត្តឡើងជាបន្តបន្ទាប់ នៅទីក្រុងប៉ារីស ក្រុងហ្សាកាតា ក្រុងតូក្យូ ក្រុងប៉ាតាយ៉ា
- ថ្ងៃទី៣០កក្កដា-៣០សីហា១៩៨៩ សន្និសីទអន្តរជាតិលើកទី១នៅក្រុងប៉ារីស បានបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC) នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩០។ក្រុមប្រឹក្សានេះប្រជុំឲលើក នៅក្រុងបាងកក ក្រុងប៉ារីស ក្រុងញូវយ៉ក ក្រុងហ្សាកាតា ក្រុងប៉េកាំង

សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

- ថ្ងៃទី២៣-២៤ មិថុនា ១៩៩១ នៅទីក្រុងប៉ាតាយ៉ា ភាគីខ្មែរទាំង៤បានស្រុះស្រួលគ្នាពីគម្រោងដោះស្រាយបញ្ហាជាតិ
- ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ សន្និសីទអន្តរជាតិលើកទី២នៅទីក្រុងប៉ារីស ភាគីខ្មែរទាំង៤ ប្រទេសពាក់ព័ន្ធចំនួន១៨ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាព





សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

❖ កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស (ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១)

- ប្រទេសដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១មាន៖
  - សហរដ្ឋអាមេរិក សហភាពសូវៀត ចក្រភពអង់គ្លេស សាធារណរដ្ឋបារាំង សាធារណរដ្ឋប្រជាមានិតចិន
  - ប្រទេសថៃ វៀតណាម ឡាវ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ព្រុយនេ សឹង្ហបុរី ហ្វីលីពីន
  - កាណាដា អូស្ត្រាលី ឥណ្ឌា ជប៉ុន យូហ្គោស្លាវី

សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

❖ កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស (ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១)

- កិច្ចព្រមព្រៀងនេះផ្តោតលើចំណុចសំខាន់ៗ២គឺ ៖
  - បញ្ហាអធិបតេយ្យភាព បូរណភាពទឹកដី និងឯករាជ្យភាពនៃកម្ពុជា
  - បញ្ហាស្តារ និងកសាងប្រទេសកម្ពុជាឡើងវិញ







សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)

❖ អ៊ុន តាក់ (អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា):

បេសកកម្ម(UNTAC)

- ១. ដកអាវុធពីភាគីទាំង៤
- ២. បញ្ចូលវដ្ឋអំណាចទាំងសងខាង
- ៣. រៀបចំការបោះឆ្នោត
- ៤. នាំជនភៀសខ្លួនមកមាតុភូមិ

សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)









ពង្រឹងពុទ្ធិ

សំណួរពហុជ្រើសរើស

ពង្រឹងពុទ្ធិ

១. តើរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា រំដោះប្រទេសពីរបបកម្ពុជាប្រជាធិបតេយ្យបានជោគជ័យ នៅថ្ងៃ ខែ ឆ្នាំណា?

ចម្លើយ

ក. ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨

ខ. ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨

គ. ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩

ឃ. ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩

ពេញចុងក្រៃ

**១. តើរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា រំដោះប្រទេសពីរបបកម្ពុ
ជាប្រជាធិបតេយ្យបានជោគជ័យ នៅថ្ងៃ ខែ ឆ្នាំណា?**

ចម្លើយ

ឃ. ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩

ពង្រឹងពុទ្ធិ

២. តើឥស្សរជនណា ជាប្រធានរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ?

ចម្លើយ

ក. សមមិត្ត ហេង សំរិន

ខ. សមមិត្ត ជា ស៊ីម

គ. សមមិត្ត ហ៊ុន សែន

ឃ. សមមិត្ត ប៉ែន សុវណ្ណ

ពង្រឹងពុទ្ធិ

២. តើឥស្សរជនណា ជាប្រធានរណសិរ្សសាមគ្គី សង្គ្រោះជាតិកម្ពុជា ?

ចម្លើយ

ក. សមមិត្ត ហោ ស៊ំរិន

ពេញចិត្ត

៣.តើរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា មានរយៈកាលពីឆ្នាំណា ដល់ឆ្នាំណា?

ចម្លើយ

ក. ឆ្នាំ១៩៧៥-១៩៨៨

ខ. ឆ្នាំ១៩៧៥-១៩៨៩

គ. ឆ្នាំ១៩៧៥-១៩៩0

ឃ. ឆ្នាំ១៩៧៥-១៩៩១

ពេជ្រឹចពុទ្ធិ

៣. តើរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា មានរយៈកាលពីឆ្នាំណា ដល់ឆ្នាំណា?

ចម្លើយ

ខ. ឆ្នាំ ១៩៧៥-១៩៨៩

ពេលវេលាគុំទិ

៤. តើសភាជាតិបានអនុម័តរដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានៅថ្ងៃ ខែ ឆ្នាំណា?

ចម្លើយ

ក. ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨

ខ. ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨

គ. ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩

ឃ. ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១

ពេញចុងក្រៃ

៤. តើសភាជាតិបានអនុម័តរដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានៅថ្ងៃ ខែ ឆ្នាំណា?

ចម្លើយ

ឃ. ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១

ពេញចុងក្តី

៥. តើឥស្សរជនណា ជាប្រធានក្រុមប្រឹក្សារដ្ឋនៃរបប សាធារណរដ្ឋប្រជាមានិតកម្ពុជា?

ចម្លើយ

ក. សមមិត្ត ហេង សំរិន

ខ. សមមិត្ត ជា ស៊ីម

គ. សមមិត្ត ហ៊ុន សែន

ឃ. សមមិត្ត ប៉ែន សុភណ្ណ

ពេញចុងក្នុង

៥. តើឥស្សរជនណា ជាប្រធានក្រុមប្រឹក្សារដ្ឋនៃរបប សាធារណរដ្ឋប្រជាមានិតកម្ពុជា?

ចម្លើយ

ក. សមមិត្ត ហេង សំរិន

ពេញចិត្ត

៦.តើគណបក្សប្រជាជនបដិវត្តន៍កម្ពុជា បច្ចុប្បន្ន មានឈ្មោះដូចម្តេច?

ចម្លើយ

ក. គណបក្សរណសិរ្សខ្មែរ

ខ. គណបក្សកុម្មុយនីស្ត

គ. គណបក្សយុវជនកម្ពុជា

ឃ. គណបក្សប្រជាជនកម្ពុជា

ពេញចុងក្រៅ

៦. តើគណបក្សប្រជាជនបដិវត្តន៍កម្ពុជា បច្ចុប្បន្ន មានឈ្មោះដូចម្តេច?

ចម្លើយ

ឃ. គណបក្សប្រជាជនកម្ពុជា

ពេញមួយភូមិ

៧. តើរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានបង្កើតកាតព្វយោធារយៈពេល៥ឆ្នាំនៅថ្ងៃ ខែ ឆ្នាំណា?

ចម្លើយ

ក. ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៨៤

ខ. ថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៨៥

គ. ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧

ឃ. ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៨៩

ពេញចុងក្រៅ

៧. តើរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានបង្កើតកាតព្វយោធារយៈពេល៥ឆ្នាំដោយថ្ងៃ ខែ ឆ្នាំណា?

ចម្លើយ

ខ. ថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៨៥

ពេញចិត្ត

៨. តើឥស្សរជនណា ជាប្រធានរដ្ឋាភិបាលសម្ព័ន្ធត្រីភាគី?

ចម្លើយ

ក. សម្តេចនរោត្តម សីហនុ

ខ. លោក ស៊ឺន សាន

គ. លោក ខៀវ សំផន

ឃ. សាឡុត ស (ប៉ុល ពត)

ពេជ្រឹងពុទ្ធិ

៨. តើឥស្សរជនណា ជាប្រធានរដ្ឋាភិបាលសម្ព័ន្ធត្រីភាគី?

ចម្លើយ

ក. សម្តេចនរោត្តម សីហនុ

ពេញមួយភូមិ

៩. តើរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាក់ឱ្យចរាចរណ៍ក្រជាសប្រាក់នៅឆ្នាំណា?

ចម្លើយ

ក. ឆ្នាំ១៩៧៩

ខ. ឆ្នាំ១៩៨0

គ. ឆ្នាំ១៩៨១

ឃ. ឆ្នាំ១៩៨២

ពេញចុងក្រៅ

៩. តើរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាក់ឱ្យ ចរាចរណ៍ក្រជាសប្រាក់នៅឆ្នាំណា ?

ចម្លើយ

ខ. ឆ្នាំ១៩៨០

ពេញចុងក្ដិ

១០. តើរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបង្កើតក្រុមឈ្មោះអ្វីដើម្បីជួយដល់ជីវភាពស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរា?

ចម្លើយ

ក. សហគ្រណ៍កម្រិតទាប

ខ. សហគ្រណ៍កម្រិតខ្ពស់

គ. ក្រុមសាមគ្គីបង្កបង្កើនផល

ឃ. ក្រុមសង្គ្រោះបន្ទាន់

ពេលវេលាសិក្សា

១០. តើរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានដើរតួនាទីយ៉ាងណាខ្លះ ដើម្បីជួយដល់ជីវភាពស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរា...?

ចម្លើយ

ក. ក្រុមសាមគ្គីបក្ខពលើនផល

ពេជ្រឹងពុទ្ធិ

១១.តើសហរដ្ឋអាមេរិកផ្តល់ប្រាក់ឱ្យគាគីណា នៅដើមទសវត្សរ៍ឆ្នាំ៨0 ដាសតវត្សទី២0?

ចម្លើយ

ក. សាធារណរដ្ឋប្រជាមានិតកម្ពុជា

ខ. កម្ពុជាប្រជាធិបតេយ្យ

គ. រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ

ឃ. ហ្វ៊ុនស៊ិនប៉ិច (FUNCINPEC)

ពង្រឹងពុទ្ធិ

១១. តើសហរដ្ឋអាមេរិកផ្តល់ប្រាក់ឱ្យតាគីណា នៅដើមទសវត្សរ៍ឆ្នាំ៨0 នាសតវត្សទី២0?

ចម្លើយ

ខ. កម្ពុជាប្រជាធិបតេយ្យ

ពេលវេលាគុណ

១២.តើនាគីមួយណា ដែលរំដោះប្រជាជនកម្ពុជា ពីរបបប្រល័យពូជសាសន៍ ប៉ុល ពត?

ចម្លើយ

ក. សាធារណរដ្ឋប្រជាមានិតកម្ពុជា

ខ. កម្ពុជាប្រជាធិបតេយ្យ

គ. រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ

ឃ. ហ្វ៊ុនស៊ិនប៉ិច (FUNCINPEC)

ពេញចុងក្រៅ

១២. តើនាគីមួយណា ដែលរំដោះប្រជាជនកម្ពុជា ពីរបបប្រល័យពូជសាសន៍ ប៉ុល ពត?

ចម្លើយ

ក. សាធារណរដ្ឋប្រជាមានិតកម្ពុជា

ពេញចិត្ត

១៣. តើកំណែទម្រង់ពេរ៉ៃស្តុយយកា នៅសហគាពសូវៀតធ្វើឡើងនៅឆ្នាំណា?

ចម្លើយ

ក. ឆ្នាំ១៩៨៥

ខ. ឆ្នាំ១៩៨៦

គ. ឆ្នាំ១៩៨៧

ឃ. ឆ្នាំ១៩៨៨

ពេញចិត្ត

១៣. តើកិច្ចសម្រេចពេទ្យស្តីពីយកា នៅសហគមន៍ស្ងៀតធ្វើឡើងនៅឆ្នាំណា?

ចម្លើយ

ក. ឆ្នាំ១៩៨៥

ពេញចិត្ត

១៤. តើមានព្រឹត្តិការណ៍ ជាប្រវត្តិសាស្ត្រអ្វីកើតឡើងនៅកម្ពុជា នាថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៨៩?

ចម្លើយ

ក. ការដកទ័ពខ្មែរក្រហម

ខ. ការដកទ័ពវៀតណាម

គ. ការដកកងទ័ពចារាំង

ឃ. ការដកកងទ័ពវៀតកុង

ពេញចុងក្រៅ

១៤. តើមានព្រឹត្តិការណ៍ ជាប្រវត្តិសាស្ត្រអ្វីកើតឡើងនៅកម្ពុជា នាថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៨៩ ?

ចម្លើយ

ខ. ការជកជំពៀតលាម

ពេជ្រឹចពុទ្ធិ

១៥.តើប្រទេសកម្ពុជា លុបចោលទូទាសប្រហារជីវិត នៅឆ្នាំណា ?

ចម្លើយ

ក. ឆ្នាំ ១៩៨៧

ខ. ឆ្នាំ ១៩៨៨

គ . ឆ្នាំ ១៩៨៩

ឃ. ឆ្នាំ ១៩៩0

ពេញចុងក្រៅ

១៥. តើប្រទេសកម្ពុជា លុបចោលទូទាំងទោសប្រហារជីវិត នៅឆ្នាំណា?

ចម្លើយ

ក. ឆ្នាំ ១៩៨៩

ពេញចុងក្ដី

១៦. តើជំនួបជំបួងរវាងសម្តេចនរោត្តម សីហនុ និងលោក ហ៊ុន សែន នៅទីក្រុងហ្សឺណែវ ប្រព្រឹត្តទៅនៅថ្ងៃ ខែ ឆ្នាំណា?

ចម្លើយ

ក. ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨

ខ. ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧

គ. ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៨

ឃ. ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៩

ពេញពុទ្ធិ

១៦. តើដំណួបដំបូងរវាងសម្តេចនរោត្តម សីហនុ និងលោក ហ៊ុន សែន នៅទីក្រុងហ្សឺអង់តាដឺន៍ ប្រព្រឹត្តទៅនៅថ្ងៃ ខែ ឆ្នាំ ណា?

ចម្លើយ

ខ. ថ្ងៃទី២ ខែឆ្នូ ឆ្នាំ១៩៨៧

ពង្រឹងពុទ្ធិ

១៧. តើឥស្សរជនណា ជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ?

ចម្លើយ

ក. សម្តេចនរោត្តម សីហនុ

ខ. សម្តេច ហ៊ុន សែន

គ. សម្តេច ហេង សំរិន

ឃ. សម្តេច ជា ស៊ីម

ពេញចុងក្ដី

១៧. តើឥស្សរជនណា ជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់?

ចម្លើយ

ក. សម្តេចនរោត្តម សីហនុ

ពេញចិត្ត

១៨.តើអង្គការបណ្តោះអាសន្នណានៃអង្គការសហប្រជាជាតិនៅកម្ពុជាហៅកាត់យ៉ាងដូចម្តេច?

ចម្លើយ

ក. សេអាតូ(SEATO)

ខ. អូតាស់(OTASE)

គ . អេសអ៊ិនស៊ី(SNC)

ឃ. អ៊ុនតាក់(UNTAC)

ពេជ្រឹចពុទ្ធិ

១៨. តើអង្គចរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជាហៅកាត់យ៉ាងដូចម្តេច?

ចម្លើយ

ឃ. អ៊ុនតាក់(UNTAC)

សំណួរ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា

សំណួរទី១ : រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបង្កើតនៅឆ្នាំណា ? តើរណសិរ្សនេះបានបំពេញបេសកកម្មដូចម្តេចខ្លះចំពោះជាតិ មាតុភូមិ ?

សំណួរទី២ : តើរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា រំដោះប្រទេសជាតិពីរបបកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំណា ? តើជ័យជម្នះ នេះមានអត្ថន័យជាប្រវត្តិសាស្ត្រដូចម្តេចខ្លះ ?

សំណួរទី៣ : ចូរបង្ហាញពីស្ថានភាពប្រជាជនកម្ពុជាក្រោយថ្ងៃទី៧មករា ១៩៧៩ ។

សំណួរទី៤ : ចូរបង្ហាញពីវិស័យអប់រំនៅកម្ពុជាមុន និងក្រោយឆ្នាំ ១៩៧៩ ។

សំណួរទី៥ : ចូរបង្ហាញពីការស្តារ ទ្បើងវិញនូវវិស័យសេដ្ឋកិច្ច សង្គមនៅកម្ពុជាក្រោយឆ្នាំ ១៩៧៩ ។

សំណួរ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា

សំណួរទី៦ : ចូរបង្ហាញពីការបែកបាក់ជាតិកម្ពុជា ក្រោយឆ្នាំ១៩៧៩ ។

សំណួរទី៧ : តើរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា(រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា)ចាត់វិធានការយ៉ាងដូចម្តេចខ្លះដើម្បីទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ ?

សំណួរទី៨ : ហេតុអ្វីបានជាសភារបបសាធារណរដ្ឋប្រជាមានិតកម្ពុជាធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ ?តើសភាអនុម័តយ៉ាងដូចម្តេចខ្លះ ?

សំណួរទី៩ : តើព្រឹត្តិការណ៍ណាខ្លះដែលអំណោយផល(ផ្តល់បច្ច័យល្អ)ដល់ការចរចារកសន្តិភាពនៅកម្ពុជា នាទសវត្សរ៍ឆ្នាំ ៨០-៩០ ?

សំណួរ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា

សំណួរទី១០ : ចូរពណ៌នាពីការចរចារកសន្តិភាព និងការបង្រួបបង្រួមជាតិ នៅកម្ពុជា ។

សំណួរទី១១ : ចូររាប់ឈ្មោះប្រទេស ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីសថ្ងៃទី ២៣ខែតុលា ឆ្នាំ១៩៩១ ឱ្យបាន៥ ? តើកិច្ចព្រមព្រៀងនេះមានខ្លឹមសារសំខាន់ៗ អ្វីខ្លះ ?


សំណួរទី១២ : ចូរបង្ហាញពីតួនាទីរបស់សម្តេច នរោត្តម សីហនុ និង សម្តេចហ៊ុន សែន ក្នុងការចរចារកសន្តិភាព និងបង្រួបបង្រួមជាតិ។

សំណួរទី១៣ : រហេតុអ្វីបានជាគេចាត់ទុកថា សម្តេច នរោត្តម សីហនុ និង សម្តេចហ៊ុន សែន ជាបិតាសន្តិភាព និងការបង្រួបបង្រួមជាតិនៅកម្ពុជា។

កិច្ចការផ្ទះ

តើកិច្ចព្រមព្រៀងក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ ១៩៩១ ពិតជានាំសន្តិភាពពេញលេញ ជូនប្រទេសកម្ពុជាដែរ ឬទេ ? ព្រោះហេតុអ្វី ?







អរគុណ!



MEAS PHYRUN

ប្រវត្តិសាស្ត្រកម្ពុជា